ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបឯកឧត្តមឯកអគ្គរដ្ឋទូតសហព័ន្ធរុស្សីប្រចាំកម្ពុជា





នៅព្រឹកថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម បានទទួលជួបឯកឧត្តម **Dmitry Tsvetos** ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្សីប្រចាំកម្ពុជា ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសំដែងការស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះលទ្ធផលនៃការបំពេញបេសកកម្មការទូតរបស់ឯកឧត្តម **Dmitry Tsvetos** នៅកម្ពុជា ក្នុងការជម្រុញទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ក៏ដូចជាវិស័យទេសចរណ៍ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានសម្តែងនូវការដឹងគុណចំពោះ អតីតសហភាព

សូវៀត ដែលបានផ្តល់ជំនួយឧបត្ថម្ភ និងជំនួយសង្គ្រោះជាច្រើនដល់កម្ពុជា ក្នុងកាលៈទេសៈដែលកម្ពុជា ទើបរំដោះរួចផុតពីរបបប្រល័យពូជសាសន៍ប៉ុលពត ។

ឯកឧត្តម **Dmitry Tsvetos** ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្សីប្រចាំកម្ពុជា បានវាយតម្លៃខ្ពស់ចំពោះភាពរីកចម្រើនលើគ្រប់វិស័យរបស់កម្ពុជា និងបានលើកឡើងពីអត្ថប្រយោជន៍នៃការប្រើប្រាស់ឱ្យអស់លទ្ធភាពនៃសក្តានុពលរបស់ប្រទេសទាំងពីរ ក្នុងការលើកកំពស់ការអភិវឌ្ឍន៍សម្រាប់ទាំងអស់គ្នា។ ក្នុងនោះវិស័យឧស្សាហកម្ម ឯកឧត្តម ឯកអគ្គរដ្ឋទូត បានស្នើឱ្យក្រសួងឧស្សាហកម្ម នៃប្រទេសទាំងពីរ កម្ពុជា–រុស្សី រៀបចំផែនទីបង្ហាញផ្លូវ ដើម្បីកំណត់វិស័យអាទិភាពមួយចំនួន ក្នុងការទាក់ទាញវិស័យវិនិយោគពីរុស្សីមកកម្ពុជា ។ ឯកឧត្តម ឯកអគ្គរដ្ឋទូត រុស្សី បានបញ្ជាក់ថាៈវិស័យដែលរុស្សីចាប់អារម្មណ៍ថ្មីៗនៅកម្ពុជារួមមាន ៈការបង្កើតរោងចក្រតម្លើង ត្រាក់ទ័រ និងគ្រឿងយន្តកសិកម្ម– រោងចក្រតម្លើងកប៉ាល់ដឹកទំនិញតាមផ្លូវសមុទ្រ–រោងចក្រផលិតថាមពលអគ្គិសនី ដើរដោយពន្លឺព្រះអាទិត្យ –ការរុករកប្រេង និងឧស្ម័ន និងបំណងពិនិត្យលទ្ធភាពបង្កើតរោងចក្រអគ្គិសនីដើរដោយថាមពលនុយក្លេអ៊ែផងដែរ ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសាទរចំពោះវិស័យដែលជាមុខសញ្ញាវិនិយោគរបស់ក្រុមហ៊ុនរុស្សីខាងលើ ។ ក្នុងនោះដូចជាៈរោងចក្រផលិតកប៉ាល់ដឹកទំនិញតាមផ្លូវសមុទ្រ គឺ ជាមុខសញ្ញាវិនិយោគថ្មី ដែលត្រូវយកចិត្តទុកដាក់ ហើយការផលិតរោងចក្រតម្លើងត្រាក់ទ័រ និងគ្រឿងយន្តកសិកម្ម គឺបានស្ថិតក្នុងគោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលស្រាប់ ។ ជាមួយគ្នានេះ ការុករកប្រេង និងឧស្ម័ន កម្ពុជានៅតែស្វាគមន៍ចំពោះក្រុមហ៊ុនទានាដែលមានជំនាញ និងបទពិសោធន៍ខ្ពស់ សម្រាប់ការរុករកនៅតំបន់ផ្សេងៗទៀត ។ ចំពោះការផលិតថាមពលអគ្គិសនីកម្ពុជាលើកទឹកចិត្ត ទាំងអគ្គិសនីដើរដោយកំលាំងទឹក ខ្យល់ និងពន្លឺព្រះអាទិត្យ ។ ដោយឡែកការផលិតអគ្គិសនី ដើរដោយថាមពលនុយក្លេអ៊ែ ជាទស្សនៈរបស់ឯកឧត្តមផ្ទាល់ ឯកឧត្តមមានការរារែក ពីព្រោះប្រទេសកម្ពុជា ជាប្រទេសតូចត្រូវមានការប្រុងប្រយ័ត្នបំផុតពីផលប៉ះពាល់បរិស្ថាន និងឥទ្ធិពលនៃវិទ្យុសកម្ម ជាយថាហេតុ ទោះការបង្កើតរោងចក្រ

នៅកម្ពុជា ជាទីតាំងមានសុវត្ថិភាពខ្ពស់ក៏ដោយ ។ ទោះជាយ៉ាងណា ឯកឧត្តម ទេសរដ្ឋមន្ត្រីបានស្នើឱ្យលើកបញ្ហានេះទៅក្រសួងជំនាញ គឺក្រសួងរ៉ែ និងថាមពល ។